**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ដើម្បីជួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការពិនិត្យស្រាវជ្រាវ និងកសាងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងក្រសួងមហាផ្ទៃ រួមចំណែកក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល ។

មាត្រា២ .-

ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ មានភារកិច្ច ៖

- សហការជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ក្នុងការលើកផែនការ ការងារកសាងលិខិតបទដ្ឋានគតិយុត្ត និងឯកសារចាំបាច់ផ្សេងទៀតរបស់ក្រសួងមហាផ្ទៃ ឱ្យស្របតាមអាទិភាព នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សហការសិក្សាស្រាវជ្រាវជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីតាក់តែង រៀបរៀងសេចក្តីព្រាង លើកគម្រោងនៃការតាក់តែង កសាង និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាដែលបំរើសកម្មភាពរបស់ក្រសួងមហាផ្ទៃ
- ពិនិត្យខ្លឹមសារសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា ដែលអង្គភាពទាំងឡាយចំណុះក្រសួងមហាផ្ទៃបានតាក់តែងរួចហើយ មុននឹងដាក់ឆ្លងមតិថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដោយធ្វើការសិក្សាបំពេញបន្ថែមខ្លឹមសារដែលនៅចន្លោះប្រហោង ឬកាត់បន្ថយខ្លឹមសារណាដែលយល់ឃើញថាមិនសមស្រប
- សហការតាមដាន ត្រួតពិនិត្យ ដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សិក្សា និងតាមដានលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលមិនសមស្របទៅនឹងសភាពការណ៍ជាក់ស្តែងដើម្បីលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងធ្វើវិសោធនកម្មឱ្យស្របតាមស្ថានភាពអភិវឌ្ឍន៍នៃប្រទេសជាតិ
- សិក្សា និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អំពីសេចក្តីព្រាងលិខិតូបករណ៍នានា ដែលពាក់ព័ន្ធនឹងក្រសួងមហាផ្ទៃ
- តាមដានលើការអនុវត្ត និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា
- សហការចាត់ចែងរៀបចំបំពេញបែបបទក្នុងការបញ្ជូនសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យនានាទៅរាជរដ្ឋាភិបាលក្រោយពីមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរួចហើយ
- សិក្សាស្រាវជ្រាវ តាក់តែងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា តាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ចូលរួមជាមួយគណៈកម្មាធិការ ឬ ក្រុមការងារតាក់តែងលិខិតបទដ្ឋានគតិយុត្ត ឬអង្គភាពជំនាញ ឬ ក្រសួង ស្ថាប័ននានា តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
- ចូលរួមក្នុងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សហការរៀបចំការបណ្តុះបណ្តាលដល់មន្ត្រីក្រោមឱវាទរបស់ក្រសួងមហាផ្ទៃលើការងារពាក់ព័ន្ធនឹងច្បាប់
- តំណាងឱ្យក្រសួងមហាផ្ទៃចូលរួមប្រជុំជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល តាមការចាត់តាំងពីថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
- គ្រប់គ្រងបណ្ណាល័យក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ និងចែកផ្សាយសៀវភៅរាជកិច្ច និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់ការងាររដ្ឋបាល នគរបាលជាតិនៅទីស្តីការក្រសួងមហាផ្ទៃ និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់
- ចងក្រងបោះពុម្ពជាសៀវភៅច្បាប់សម្រាប់ចែកចាយផ្សព្វផ្សាយ
- សហការជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលចាំបាច់

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។

**មាត្រា៣ .-**

រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សានីតិកម្ម ត្រូវបានកំណត់ដូចខាងក្រោម ÷

-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនគរបាល

-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តរដ្ឋបាល

-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តក្រសួង ស្ថាប័ន នានា

-ក្រុមស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

-លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម

**មាត្រា៤ .-**

ក្រុមប្រឹក្សានីតិកម្ម មានសមាសភាព ប្រធាន អនុប្រធាន និងសមាជិក។

ក្រុមប្រឹក្សានីតិកម្មត្រូវបានដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធានក្រុមប្រឹក្សានីតិកម្ម មានថ្នាក់ស្មើអនុរដ្ឋលេខាធិការ អនុប្រធានក្រុមប្រឹក្សានីតិកម្ម មានថ្នាក់ស្មើអគ្គនាយក នៃអគ្គនាយកដ្ឋាននានារបស់ក្រសួងមហាផ្ទៃ។

សមាជិកក្រុមប្រឹក្សានីតិកម្មគ្រប់រូប មានថ្នាក់ស្មើប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ។

**មាត្រា៥ .-**

សមាជិកក្រុមប្រឹក្សានីតិកម្ម ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់ នៃក្របខ័ណ្ឌរបស់ក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រ ចាប់ពីបរិញ្ញាប័ត្រឡើងទៅ និងមានបទពិសោធន៍លើការងារកសាងលិខិតបទដ្ឋានគតិយុត្ត។

**មាត្រា៦ .-**

សមាជិកក្រុមប្រឹក្សានីតិកម្មម្នាក់ៗ ត្រូវបានចាត់តាំងបញ្ចូលទៅក្នុងក្រុមស្រាវជ្រាវនីមួយៗ។ ក្រុមស្រាវជ្រាវនីមួយៗត្រូវមានសមាជិកក្រុមប្រឹក្សានីតិកម្មយ៉ាងតិច ៥រូប ដឹកនាំដោយប្រធាន ១រូប ចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមសំណើរបស់ប្រធានក្រុមប្រឹក្សានីតិកម្ម។

ក្នុងករណីប្រធានអវត្តមាន ប្រធានក្រុមប្រឹក្សានីតិកម្ម ត្រូវចាត់តាំងសមាជិកក្រុមប្រឹក្សានីតិកម្មណាម្នាក់ នៅក្នុងក្រុមស្រាវជ្រាវជាមួយ ជាប្រធានស្តីទីជំនួស។

**មាត្រា៧ .-**

តួនាទី និងភារកិច្ចរបស់ក្រុមស្រាវជ្រាវនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៨ .-**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ជាសេនាធិការឱ្យក្រុមប្រឹក្សានីតិកម្ម សម្រាប់ចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ធ្វើកំណត់ហេតុគ្រប់ពេលប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម និងធ្វើកិច្ចការផ្សេងៗ តាមសំណូមពររបស់ក្រុមប្រឹក្សានីតិកម្ម។

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានថ្នាក់ស្មើនាយកដ្ឋានចំណុះអគ្គនាយកដ្ឋាននានារបស់ក្រសួងមហាផ្ទៃ។

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៩ .-**

លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានថ្នាក់ស្មើនឹងប្រធាននាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ។

អនុប្រធានលេខាធិការដ្ឋាន មានថ្នាក់ស្មើនឹងអនុប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ។

**មាត្រា១០ .-**

ប្រធានក្រុមប្រឹក្សានីតិកម្ម មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំអង្គភាពនានាក្រោមឱវាទក្រសួងមហាផ្ទៃ មកចូលរួមកិច្ចប្រជុំការងារ ឬមកបំភ្លឺលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។

**មាត្រា១១ .-**

មាត្រាទាំងឡាយនៃអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥ ដែលពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សានីតិកម្ម និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី..១៨ ខែ..តុលា....ឆ្នាំ២០០៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខា**

**ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**